ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១០...សសរ

សេចក្តីសំរេច

ស្តីពី

ការកែសម្រួល និងបំពេញបន្ថែមសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិ គ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា

~~~~~~~~~~~~~~~~

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១១៩៨ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦ ០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស រកម ០១០៥ ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងអនុស្សារណៈយោគយល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអូស្ត្រាលី ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- យោងអនុស្សារណៈ ស្តីពីការរៀបចំចាត់ចែងទាក់ទងនឹងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៧

www.pheakdeylaw.com
~~~~~~~~~~~~~~~~

- យោងសេចក្តីសំរេចលេខ ២៥ សសរ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
- យោងសេចក្តីសំរេចលេខ ៥៣ សសរ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកែសម្រួលសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា។

## សំរេច

**ប្រការ១:** ត្រូវបានបំពេញបន្ថែមសមាជិកគណៈកម្មាធិការប្រតិបត្តិ ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តម **អ៊ុំ សារិទ្ធ** អភិបាលខេត្តព្រៃវែង សមាជិក

២- ឯកឧត្តម **ប្រាជ្ញ ចន្ទ** អភិបាលខេត្តបាត់ដំបង សមាជិក

៣- លោក **គង់ នាន** អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក និងជាជនបង្គោល។

**ប្រការ២:** ត្រូវបានបន្ថែមតួនាទីជូនលោកឧត្តមសេនីយ៍ **នួន ប៊ុនថល** អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ក្រសួងមហាផ្ទៃ ជាប្រធានក្រុមពិគ្រោះយោបល់ និងជាសហប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា។

**ប្រការ៣:** ត្រូវបានកែសម្រួលជាសមាជិកជនបង្គោលលេខាធិការដ្ឋាន ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ជាជនបង្គោល ផ្នែកក្រសួងយុត្តិធម៌ និងតុលាការ ជំនួសលោក **នុច ពាធ**

២- ឯកឧត្តម **ង៉ែ សុខខេង** ប្រធានក្រុមគម្រោងប្រព័ន្ធយុត្តិធម៌នៃអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាសមាជិកក្រុមពិគ្រោះ

www.pheakdeylaw.com

យោបល់ និងជាជនបង្គោលផ្នែកគាំទ្រកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជំនួសលោក **សួង លាងហៃ**។

**ប្រការ៤:** ត្រូវបានកែសម្រួល និងបំពេញបន្ថែមសមាជិកក្រុមពិគ្រោះយោបល់ ដែលមានសមាសភាពដូចខាងក្រោម :

១- លោក **យឹម សុខុម** អភិបាលរងខេត្តព្រៃវែង ជាសមាជិក (ជនបង្គោល)

២- លោក **អ៊ុក ច័ន្ទ** អភិបាលរងខេត្តបាត់ដំបង ជាសមាជិក (ជនបង្គោល)

៣- លោក **អ៊ុក គីមសិទ្ធិ** ព្រះរាជអាជ្ញាអមតុលាការ ខេត្តកណ្តាល ជាសមាជិក ជំនួសលោក **ហ៊ួត ទុន្ទី**

៤- លោក **ឆេត តារុន** អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ ជាសមាជិក

៥- លោក **អ៊ុំ សុគំណា** មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសមាជិក (ជនបង្គោល ទ.ប.ស.ស) ជំនួសលោក **ចេង ញ៉ាន់**។

**ប្រការ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា និងសាមីខ្លួនដូនមានចែងក្នុងប្រការ១ ប្រការ២ ប្រការ៣ និងប្រការ៤ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧.ខែ .មិថុនា. ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ខេង

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង

-ក្រសួង-ស្ថាប័នពាក់ព័ន្ធ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ១

-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com